**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
នាយកដ្ឋានព័ត៌មាន

# សេចក្តីជូនព័ត៌មាន

ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា និងជាសហប្រធានគណៈកម្មការអន្តររដ្ឋាភិបាលកម្ពុជា-រុស្ស៊ី ស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម សេដ្ឋកិច្ច វិទ្យាសាស្ត្រ និងបច្ចេកទេស នឹងដឹកនាំគណៈប្រតិភូអញ្ជើញទៅបំពេញទស្សនកិច្ចការងារនៅសហព័ន្ធរុស្ស៊ី ពីថ្ងៃទី២៣ ដល់ថ្ងៃទី ២៤ ខែសីហា ឆ្នាំ២០១៧។

ក្នុងអំឡុងពេលស្នាក់នៅទីក្រុងម៉ូស្គូ ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន នឹងជួបពិភាក្សាទ្វេភាគី ជាមួយឯកឧត្តម សែរហ្គៃ ឡាវរ៉ូវ (Sergey LAVROV) រដ្ឋមន្ត្រីការបរទេសសហព័ន្ធរុស្ស៊ី ដែលក្នុងនោះ ទំនាក់ទំនងទ្វេភាគី រួមទាំងបញ្ហាតំបន់ និងសកលលោក ដែលជាការព្រួយបារម្ភរួម នឹងត្រូវលើកយកមកពិភាក្សា និងផ្លាស់ប្តូរយោបល់គ្នា ។

ក្នុងអំឡុងពេលទស្សនកិច្ចនេះដែរ ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន និង ឯកឧត្តម នីកូឡៃ នីគីហ្វរ៉ូវ (Nikolay Nikiforov) រដ្ឋមន្ត្រីក្រសួងទូរគមនាគមន៍ និងព័ត៌មាន នៃសហព័ន្ធរុស្ស៊ី នឹងអញ្ជើញធ្វើជាសហប្រធាននៃកិច្ចប្រជុំលើកទី១០ របស់គណៈកម្មការអន្តររដ្ឋាភិបាលកម្ពុជា-រុស្ស៊ី ស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម សេដ្ឋកិច្ច វិទ្យាសាស្ត្រ និងបច្ចេកទេស ដែលនឹងពិនិត្យឡើងវិញលើការអនុវត្តន៍ការព្រមព្រៀងដែលបានអនុម័ត នៅក្នុងកិច្ចប្រជុំលើកទី៩ របស់គណៈកម្មការអន្តររដ្ឋាភិបាលកម្ពុជា-រុស្ស៊ី ព្រមទាំងរិះរកលទ្ធភាពផ្សេងទៀត ដែលអាចពង្រឹងកិច្ចសហប្រតិបត្តិការកម្ពុជា-រុស្ស៊ី លើគ្រប់វិស័យ ឲ្យកាន់តែប្រសើរឡើងថែមទៀត។

នៅក្រោយកិច្ចប្រជុំលើកទី១០ របស់គណៈកម្មការអន្តររដ្ឋាភិបាលកម្ពុជា-រុស្ស៊ី នេះ ឯកសារមួយចំនួនដូចខាងក្រោម ត្រូវបានគ្រោងនឹងចុះហត្ថលេខាៈ

១-កិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យនៃការប្រើប្រាស់ថាមពលនុយក្លេអ៊ែរ ក្នុងគោលបំណងសន្តិភាព រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសហព័ន្ធរុស្ស៊ី

២-អនុស្សារណៈយោគយល់គ្នា ស្តីពីការការពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវចម្រុះ និងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយចីរភាព រវាងក្រសួងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងធនធានធម្មជាតិ និងបរិស្ថាននៃសហព័ន្ធរុស្ស៊ី

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

៣-កម្មវិធីសកម្មភាពរួមគ្នា  រវាងទីភ្នាក់ងារសហព័ន្ធផ្នែកទេសចរណ៍  (សហព័ន្ធរុស្ស៊ី) និងក្រសួងទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា សម្រាប់រយៈពេល ២០១៨-២០២០

៤-ផែនការពិគ្រោះយោបល់រវាងក្រសួងការបរទេសនៃសហព័ន្ធរុស្ស៊ី និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់ឆ្នាំ ២០១៨-២០២០ និង

៥-ពិធិសារកិច្ចប្រជុំលើកទី១០នៃគណៈកម្មការអន្តររដ្ឋាភិបាលកម្ពុជា-រុស្ស៊ី ស្តីពីកិច្ចសហប្រតិ-បត្តិការពាណិជ្ជកម្ម សេដ្ឋកិច្ច វិទ្យាសាស្ត្រ និងបច្ចេកទេស។

ភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០១៧